# សារណែនាំដល់សមាជិក
# ស្តីពីការធ្វើបច្ចុប្បន្នភាពគណនីក្នុងប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម
# និងការក្រើនរំលឹកអំពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន

សមាគម TAFTAC សូមជម្រាបជូន លោក លោកស្រី ទាំងអស់ឱ្យបានជ្រាបថា យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីធានាបាននូវការអនុលោមតាមច្បាប់ និងជៀសវាងរាល់ការផាកពិន័យផ្សេងៗដែលដោះស្រាយមិនទាន់ពេលវេលា សមាគមសូមធ្វើការណែនាំ និងក្រើនរំលឹកនូវចំណុចសំខាន់ៗចំនួនពីរដូចខាងក្រោម៖

## ១. ការធ្វើបច្ចុប្បន្នភាពគណនីក្នុងប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មបាននិងកំពុងធ្វើបច្ចុប្បន្នភាព គេហទំព័រចុះបញ្ជីពាណិជ្ជកម្មដែលមានអាសយដ្ឋាន www.businessregistration.moc.gov.kh ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងស្ថិរភាពនៃប្រព័ន្ធបច្ចេកទេស។ អាស្រ័យហេតុនេះ សូមអ្នកគ្រប់គ្រងក្រុមហ៊ុន និងសហគ្រាសទាំងអស់ មេត្តាធ្វើបច្ចុប្បន្នភាពគណនីរបស់ខ្លួន តាមរយៈនីតិវិធីដូចខាងក្រោម៖

- ចូលទៅកាន់គេហទំព័រខាងលើ រួចជ្រើសរើសយកពាក្យ "ការចូលប្រព័ន្ធ (Logon)" ។
- ចុចលើពាក្យ "កំណត់លេខសម្ងាត់ឡើងវិញ" ដោយវាយបញ្ចូលឈ្មោះគណនី និងសារអេឡិចត្រូនិក (Email) ដែលលោកអ្នកកំពុងប្រើប្រាស់ជាផ្លូវការ។
- បន្ទាប់មក លោកអ្នកនឹងទទួលបានសារអេឡិចត្រូនិកបញ្ជាក់ពីប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម។
- ជាទីបញ្ចប់ សូមធ្វើការកំណត់លេខសម្ងាត់ថ្មីឡើងវិញដោយខ្លួនឯង ជាការស្រេច។

## ២. កាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន

យោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ គឺជារបៀបវារៈចាំបាច់ដែលតម្រូវឱ្យក្រុមហ៊ុននីមួយៗអនុវត្តក្នុងអំឡុងពេលមុន ៣ (បី) ខែ នៃកាលបរិច្ឆេទខួបចុះបញ្ជីពាណិជ្ជកម្មរបស់ខ្លួន ហើយក្រសួងបានអនុញ្ញាតទុករយៈពេលអនុគ្រោះចំនួន ១៥ (ដប់ប្រាំ) ថ្ងៃ បន្ថែមទៀត។

- **វិធានការពិន័យ៖** ក្នុងករណីក្រុមហ៊ុនខកខាន មិនបានបំពេញកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមការកំណត់ខាងលើ នឹងត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។
- **ចំណុចគួរកត់សម្គាល់៖** កាលបរិច្ឆេទនៃការចុះបញ្ជីសារឡើងវិញ (Re-registration) ពុំត្រូវបានចាត់ទុកជាថ្ងៃខែខួប សម្រាប់ការតម្កល់ប្រតិវេទន៍បន្តទៀតឡើយ។ ហេតុនេះ សូមសមាជិកទាំងអស់មេត្តាពិនិត្យផ្ទៀងផ្ទាត់កាលបរិច្ឆេទខួបនៃការចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួនជាលើកដំបូង ឱ្យបានត្រឹមត្រូវ ដើម្បីធ្វើការតម្កល់ប្រតិវេទន៍ឱ្យបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ប្រព័ន្ធក៏នឹងលែងផ្ញើសាររំលឹកអំពីកាលបរិច្ឆេទក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនទៀតផងដែរ។

### ៣. ព័ត៌មានទំនាក់ទំនងសម្រាប់សាកសួរព័ត៌មានបន្ថែម

ក្នុងករណីលោក លោកស្រី មានចម្ងល់ ឬតម្រូវការជំនួយផ្នែកបច្ចេកទេសក្នុងការកំណត់លេខសម្ងាត់ឡើងវិញ សូមទំនាក់ទំនងទៅកាន់ប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម (Hotline) តាមរយៈលេខ ១២៦៦ (រួចចុចលេខ ២ សម្រាប់ព័ត៌មានលម្អិតលើការងារចុះបញ្ជីពាណិជ្ជកម្ម) ឬអាចអញ្ជើញទៅកាន់នាយកដ្ឋានចុះបញ្ជី នៃក្រសួងពាណិជ្ជកម្មផ្ទាល់ ដើម្បីទទួលការណែនាំលម្អិត។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ជាអគ្គនាយក និងអ្នកគ្រប់គ្រងក្រុមហ៊ុន រោងចក្រ និងសហគ្រាស ដែលជាសមាជិក TAFTAC ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦

**សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង**
**និងផលិតផលធ្វើដំណើរនៅកម្ពុជា**

Textile, Apparel, Footwear & Travel Goods Association in Cambodia
KINGDOM OF CAMBODIA



CamEd Business School
ABA BANK NATIONAL BANK OF CANADA GROUP
Wing Bank
KB PRASAC Bank
U.S. COTTON TRUST PROTOCOL
MorganTecnica
AVERY DENNISON
KI Professional Accountants
VSD AUDIT AND ASSURANCE

TAFTAC
Textile, Apparel, Footwear & Travel Goods Association in Cambodia

# Advisory Note to Members
# On Updating Your Account in the Business Registration System
# and Reminder of Filing the Company’s Annual Declaration

According to the notification from the Ministry of Commerce (MOC) and to ensure legal compliance and avoid any penalties resulting from failure to resolve it on time, TAFTAC would like to provide guidance and remind you of two key points as follows:

## 1. Account Update in the Business Registration System

The Ministry of Commerce has been updating its business registration website (www.businessregistration.moc.gov.kh) to enhance the efficiency and stability of its technical systems. Therefore, all company and enterprise managers are requested to update their accounts through the following procedure:

- Go to www.businessregistration.moc.gov.kh and select "Logon".
- Click on "Reset Password" by entering your Account Name and the official email you are currently using.
- Following that, you will receive a confirmation email from the Business Registration System.
- Finally, proceed to set your new password yourself to complete the process.

## 2. Obligation to File the Company's Annual Declaration

In accordance with applicable laws and regulations, the filing of the Annual Declaration is a mandatory obligation that each company must fulfill within the 3 (three) months prior to the anniversary date of its business registration, and the Ministry allows an additional grace period of 15 (fifteen) days.

- **Penalty Measure:** In the event that a company fails to fulfill the obligation to file the Annual Declaration as stipulated above, it will be subject to a fine of 2,000,000 (Two Million) Riels.

- **Note:** The Re-registration date is not considered the anniversary date for subsequent Annual Declaration filings. Therefore, all members are requested to accurately verify the anniversary date of your initial company registration to ensure the timely filing of the declaration. Additionally, the system will no longer send you reminder notifications regarding the company's Annual Declaration filing date.

## 3. Contact Information for Further Inquiries

Should you have any questions or require technical assistance in resetting your password, please contact the Ministry of Commerce’s public telephone system (Hotline) at 1266 (then press 2 for

detailed information on business registration) or you may visit the Business Registration Department of the Ministry of Commerce directly to receive detailed guidance.

In this regard, please all directors and managers of companies, factories, and enterprises that are TAFTAC members be informed of this notice and comply in a highly responsible manner.

Phnom Penh, 11 May 2026

TAFTAC

Textile, Apparel, Footwear & Travel Goods Association in Cambodia

KINGDOM OF CAMBODIA

Textile, Apparel, Footwear & Travel Goods Association in Cambodia

**TAFTAC**
Textile, Apparel, Footwear & Travel Goods Association in Cambodia

# 致会员的通告

# 关于在商业注册系统中更新账户及提交公司年度申报的提醒

根据商务部（MOC）的通知，为确保合规并避免因未能及时处理而受到处罚，TAFTAC 特此提供指导并提醒您注意以下两点：

## 1. 商业注册系统中的账户更新

商务部正在对其企业注册网站（www.businessregistration.moc.gov.kh）进行升级，以提升技术系统的运行效率和稳定性。因此，请所有公司和企业负责人按照以下步骤更新其账户：

- 访问 www.businessregistration.moc.gov.kh 并选择"登录"。
- 点击“重置密码”，输入您的账户名和当前使用的官方邮箱。
- 随后，您将收到来自商业注册系统的确认邮件。
- 最后，请自行设置新密码以完成整个流程。

## 2. 提交公司年度声明的义务

根据适用法律法规，提交年度申报是每家公司必须在企业注册周年日前 3（三）个月内履行的法定义务，且该部允许额外 15（十五）天的宽限期。

- **处罚措施：**若公司未能履行上述规定的年度申报义务，将被处以 2,000,000（两百万）瑞尔的罚款。
- **注：**重新注册日期不视为后续年度申报的周年日期。因此，请所有成员准确核对公司初始注册的周年日期，以确保及时提交申报。此外，系统将不再向您发送有关公司年度申报截止日期的提醒通知。

## 3. 进一步咨询的联系方式

如果您有任何疑问，或在重置密码时需要技术协助，请致电商务部公共电话系统（热线）1266（随后按 2 键获取企业注册的详细信息），或直接前往商务部企业注册处获取详细指导。

就此，请将本通知传达给所有 TAFTAC 会员公司、工厂及企业的董事和经理，并请其以高度负责的态度予以遵守。

金边, 2026 年 05 月 11 日

**柬埔寨纺织服装制鞋箱包协会（TAFTAC）**

CamEd Business School
ABA BANK NATIONAL BANK OF CANADA GROUP
Wing Bank
KB PRASAC Bank
U.S. COTTON TRUST PROTOCOL
MoreanTecnica
AVERY DENNISON
Professional Accountants
AUDIT AND ASSURANCE



តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាលគ្រុបភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២០៩០៦
Royal Group Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantaok, Khan Kamboul, Phnom Penh, Cambodia. 120906
Tel: (855) 89 555 189 | E-mail: info@taftac-cambodia.org | Website: www.taftac-cambodia.org